**មាត្រា ៤ :** គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬ តំណាងរបស់ប្រធានស្ថាប័ន ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង និងស្ថាប័នពាក់ព័ន្ធមកចូលរួមប្រជុំ ដើម្បីដោះស្រាយការងារនៃការរៀបចំ និងការតាមដានការអនុវត្តន៍អនុស្សារណៈស្តីពីគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៥ :** គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៦ :** គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិអញ្ជើញតំណាងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ប្រចាំនៅប្រទេសកម្ពុជា អោយចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

**មាត្រា ៧ :** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលនៃធនាគារជាតិកម្ពុជា សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងគ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

ភ្នំពេញ,ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ២៦ អនក្រ.បក**

**ស្តីពីការកំណត់ឡើងវិញនូវភូមិប្រទល់រដ្ឋបាលក្រុងកែបបន្ថែម**

**ជាមួយខេត្តកំពត ត្រង់ចំណុចចំការបី**

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការប្តូរឋានៈសម្ព័ន្ធ រដ្ឋបាលក្រុងកែប ពីថ្នាក់ស្រុក មកជាថ្នាក់ក្រុង
- តាមសំណើសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : ត្រូវបានកែសំរួលព្រំប្រទល់រដ្ឋបាល រវាងក្រុងកែប និងខេត្តកំពតដោយកាត់យកផ្ទៃដីចំនួន ២០.៣០ គីឡូម៉ែត្រក្រឡា ត្រ [illegible] ប.«ចំការបី» ពីស្រុកកំពង់ត្រាចខេត្តកំពត ប្រគល់អោយក្រុងកែបគ្រប់គ្រងតាមផែនទីមាត្រដ្ឋាន ១/៥០.០០០ ដែលមានកូអរដោណេដូចខាងក្រោម :

| | X | Y |
|---|---|---|
| A- | ៦៩.០០ | ៣០.៥០ |
| B- | ៧០.០០ | ៣០.៧៥ |
| C- | ៧០.៤៥ | ៣១.២០ |
| D- | ៧០.៣៥ | ៣១.៥០ |
| E- | ៧១.០០ | ៣២.២០ |
| F- | ៧១.០០ | ៣៦.០០ |
| G- | ៦៥.២០ | ៣៦.០០ |
| H- | ៦៤.៧០ | ៣៤.២០ |

**មាត្រា ២ :** ...ារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលខេត្តកំពត និងប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកក្រុងកែបត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣ :** អនុក្រឹត្យនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

ភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ៥៣ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤